**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧៧/០០៨/២០១០

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០

**សេចក្តីសម្រេច**

លេខ : ១១២/០០៥/២០១០ កបធ.ច

ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិត ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១០ របស់ឯកឧត្តម និង លោកជំទាវ តំណាងរាស្ត្រ ចំនួន ២២រូប ដែលមានឯកឧត្តម **ស៊ិក ប៊ុនហុក** ជាតំណាង ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយអំពីសុពលភាព នៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតនេះ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០ វេលាម៉ោង ១៦ និង ១៥នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតរបស់ឯកឧត្តម និង លោកជំទាវ តំណាងរាស្ត្រចំនួន ២២រូប ដែលបានស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ អំពីសុពលភាព នៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ បានធ្វើឡើងស្របតាមមាត្រា ១៣៦ថ្មី មាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ថ្មី មាត្រា ១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើនេះមកពិនិត្យបាន
- យល់ឃើញថា សមាជរដ្ឋសភានិង ព្រឹទ្ធសភា មានចែងក្នុងមាត្រា១១៦ថ្មី និង មាត្រា១១៧ថ្មី ជំពូកទី៩ថ្មី នៃរដ្ឋធម្មនុញ្ញ ដូចតទៅ ÷

មាត្រា ១១៦._ថ្មី *ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។*

មាត្រា ១១៧._ថ្មី *បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។*

- យល់ឃើញថា មាត្រា ១៥៧ថ្មី ជំពូកទី១៦ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា ÷

មាត្រា ១៥៧._ថ្មី *នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។*

*សម្រាប់នីតិកាលទី១ នៃព្រឹទ្ធសភា :*

*-សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។*

*-ព្រះមហាក្សត្រ ទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ។*

*-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភានិង ប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ។*

*-កិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។*

តាមខ្លឹមសារនៃមាត្រា ១៥៧ថ្មីនេះ ថិរវេលាសុពលភាពនៃចំណុចទី៤ វាក្យខណ្ឌទី២ នៃមាត្រាខាងលើ មានមិនលើសពីថិរវេលានៃនីតិកាលទី១របស់ព្រឹទ្ធសភាទេ មានន័យថា កិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវដឹកនាំដោយប្រធានរដ្ឋសភា និង ប្រធានព្រឹទ្ធសភា ក្នុងឋានៈជាសហប្រធានបានតែនៅក្នុងនីតិកាលទី១នៃព្រឹទ្ធសភាតែប៉ុណ្ណោះ ។

ចំពោះកិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ក្នុងនីតិកាលជាបន្តបន្ទាប់ទៀតរបស់ព្រឹទ្ធសភា នឹងត្រូវរៀបចំ និង ប្រព្រឹត្តទៅតាមច្បាប់មួយ ដូចមានចែងក្នុងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។

## សម្រេច

**មាត្រា ១.-** បទប្បញ្ញត្តិនៃចំណុចទី៤ វាក្យខណ្ឌទី២ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**